ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦១២ / ២១-០៦-០៧

សាលដីកា

លេខ ៤១ "ក" / ០២-០៤-២០១០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ៣១-០៣-២០១០ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាក្រុមប្រឹក្សា

លោក [redacted] ជាក្រុមប្រឹក្សា

**តំណាងមហារអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៦១២ / ២១-០៦-២០០៧ រវាង

**១_ជនជាប់ចោទ**

**ក**_ឈ្មោះ [redacted]Heninz ភេទប្រុស អាយុ ៦១ ឆ្នាំ ជនជាតិអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ខណ្ឌចំការមន ក្រុងភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៨-៨-២០០៦ (ម១)។ (ប្តឹងឧទ្ធរណ៍)

_មានមេធាវីការពារលោក [redacted] **ចន្ថា ឌ**

_មានអ្នកបកប្រែភាសារអង់គ្លេស លោក [redacted] **តារា ឌ**



Scanned by CamScanner

ត្រូវចោទពីបទៈ ជួញដូរមនុស្ស និងអនាចារលើកុមារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧-៨-២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៣ . ៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់មនុស្ស និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

ខ-ឈ្មោះ [redacted] **ធីយ៉ែច** ភេទស្រី អាយុ ២២ ឆ្នាំ ជនជាតិវៀតណាម ទីលំនៅសព្វ[redacted] សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] រ ប្តីឈ្មោះ [redacted] គ្មានកូន ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៥-៨-២០០៦ (ម២) ។ (ប៉ូលីសខុទ្ទកាល័យ)

-មានមេធាវីការពារលោក [redacted] ចន្ថា ។

គ-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៤៨ ឆ្នាំ ជនជាតិវៀតណាម មានទីលំនៅដើមចាន់ [redacted] ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] រ ប្តីឈ្មោះ [redacted] មានកូន ០៣ នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៥-០៨-២០០៦ (ម២) ។ (ប៉ូលីសខុទ្ទកាល័យ)

-មានមេធាវីការពារលោក [redacted] **សុខា** ។

ត្រូវចោទពីបទៈ ជួញដូរមនុស្ស ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧-៨-២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ រាប្រង់តមនុស្ស និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

II-**ជនរងគ្រោះ**

១-ឈ្មោះ [redacted] **ចាន់ធី** ភេទប្រុស អាយុ ១២ ឆ្នាំ ជនជាតិវៀតណាម មានទី[redacted] សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

២-ឈ្មោះ [redacted] **ចាន់ថា** ភេទស្រី អាយុ ១៤ ឆ្នាំ ជនជាតិវៀតណាម [redacted] សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-មានមេធាវីការពារលោក [redacted] **ហ៊ាច** ។

៣-ឈ្មោះ [redacted] **ធីកីមយ៉ុង** ភេទប្រុស អាយុ ១៣ ឆ្នាំ មានទីលំនៅភូ[redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

៤-ឈ្មោះ [redacted] **យ៉ីវ** ភេទប្រុស អាយុ ១៤ ឆ្នាំ ជនជាតិវៀតណាម [redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។



Scanned by CamScanner

## ៦-រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ០៧-០៨-២០០៦ នៅក្រុងភ្នំពេញ មានការជួញដូរមនុស្សដែលបង្កឡើងដោយឈ្មោះ [redacted] **ធីយ៉ាវ** . ឈ្មោះ [redacted] ហុងវ៉ៃ . ឈ្មោះ [redacted] ធី . ឈ្មោះ H[redacted] Heninz និង ឈ្មោះ [redacted] Thomas ទៅលើកុមារី **ឈ្មោះ** [redacted] **ចាន់ថា** . **ឈ្មោះ** [redacted]**ធី និង ឈ្មោះ** [redacted] **ជីតឹមធី** ដោយមានការឃុំទុក(រួមភេទ) ក្នុងផ្ទះរយៈពេល ០១ អាទិត្យ ។

-**បាន**ឃើញសាលក្រមលេខ ៤៤ "ខ" ចុះថ្ងៃទី ០៩-០៣-២០០៧ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេចសេចក្តីដូចខាងក្រោម :

**១-ផ្តន្ទាទោស** :

**ក**-ឈ្មោះ [redacted] **ធីយ៉ាវ** ភេទស្រី អាយុ ២២ ឆ្នាំ ជាតិវៀតណាម

**ខ**-ឈ្មោះ [redacted]**ហុងវ៉ៃ** ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិវៀតណាម

ដាក់ពន្ធនាគារ កំណត់ក្នុងម្នាក់ៗ ចំនួន ១៧ ឆ្នាំ (ដប់ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ១៩-០៨-២០០៦ ។

**គ**-ឈ្មោះ [redacted] **ធី** ភេទស្រី អាយុ ៤៨ ឆ្នាំ ជាតិវៀតណាម

ដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ១៩-០៨-២០០៦

**ឃ**-ឈ្មោះ H[redacted] Heninz ភេទប្រុស អាយុ ៦០ ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ គិតចាប់ពីថ្ងៃ ចាប់ខ្លួនថ្ងៃទី ១៩-០៨-២០០៦ ។

ពីបទ **ជួញដូរមនុស្ស** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែ កក្កដា . សីហា ឆ្នាំ ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោស តាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ។ ។

**២-ផ្តន្ទាទោស**

**ក**-ឈ្មោះ [redacted] ភេទប្រុស អាយុ ៦០ ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ គិតចាប់ពីថ្ងៃផុតកំណត់ ទណ្ឌកម្មនៃបទល្មើសក្នុងចំណុច ១ ខាងលើនេះ ។

**ខ**-ឈ្មោះ [redacted] Thomas ភេទប្រុស អាយុ ៤២ ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ គិតចាប់ពីថ្ងៃ ចាប់ខ្លួនថ្ងៃទី ២១-០៨-២០០៦ ។

ពីបទ : **ប្រព្រឹត្តអំពើរអនាចារលើកុមារ** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែកក្កដា . សីហា ឆ្នាំ ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោស តាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ។



///

Scanned by CamScanner

៣_វត្ថុតាង :

ក-លិខិតឆ្លងដែនមានលេខ ១/ ៣៣៤៥០០៥៤ ៤០ . ២/ ៩៥០៦៣៧៥៧៣៥ . ៣/ ១០៣២ ១៣៦៨៤០ . ៤/ ១០៣២០៧៧៧៤៥ . ៥/១០៣២០៩៨៥៤៨ . ៦/១៣១០២៨៤៤០១ លិខិតឆ្លងដែន ចំនួន ០៦ ក្បាលត្រូវប្រគល់ឱ្យសាម៉ីខ្លួនវិញ ក្រោយពេលផុតកំណត់ទណ្ឌកម្មរួច ។

ខ-VCD . CD កាសែត Mini DV លេខ ៦ម៉ាក Sony ចំនួន ៤៣ ដុំ ខ្សែពណ៌សប្រវែង ០៥ ម៉ែត្រ មួយខ្សែ . ខ្សែពណ៌ផ្កាឈូកប្រវែង ០២ ម៉ែត្រ មួយខ្សែ វ៉ាត់ស្បែកចំនួន ០១ លិង្គសិប្បនិមិត្តចំនួន ០៦ ថ្នាំ ម៉ាក KY ១ដប សៀវភៅរូបអាសអាភាសមួយចំនួន ហ្វីលរូបអាសអាភាសមួយចំនួន ស្រោមអនាម័យមួយចំនួន ត្រូវរឹបអូស និង បំផ្លាញចោល ។

គ-ម៉ាស៊ីនថតរូបមាក Kodark ចំនួនមួយ កាមេរ៉ាថតវីដេអូម៉ាក Sony 1.5 Magapixel ចំនួនមួយ P C card ចំនួនមួយ ម៉ាស៊ីនថតរូបម៉ាក Olympus ចំនួនមួយ Platininnum card ចំនួនមួយ ID card ចំនួនមួយ ម៉ាស៊ីនថតវីដេអូម៉ាកសូនីចំនួនមួយ ទូរស័ព្ទដៃម៉ាក ណូគារ ចំនួនមួយ ធុងបាស់តូចមួយ Nicole ចំនួនពីរ ម៉ូនីទ័រ ម៉ាក Socos ចំនួនមួយ ស្កេនន័រម៉ាក HP 4850 ចំនួនមួយ ម៉ៅកំព្យូទ័រ ៣០ បន្ទះ ប្រដាប់ទប់ភ្លើង កំព្យូទ័រចំនួនមួយ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

_សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ១៦-០២-២០០៧ . ០៩-០៣-២០០៧ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩-០៣-២០០៧ ចំពោះមុខជនជាប់ចោទ . ជនរងគ្រោះ និង មេធាវី បើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**បាន**ឃើញសាលដីកាព្រហ្មទណ្ឌលេខ ៨៥ "ក" ចុះថ្ងៃទី ០៣-០៨-២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីដូចតទៅ :

**១**_ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤-០៤-២០០៧ របស់ជនជាប់ចោទឈ្មោះ[redacted] **Thomas** បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២-៣-២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] **Heninz** ឈ្មោះ [redacted] ធី . ឈ្មោះ [redacted] **ធីយ៉ី** និងឈ្មោះ[redacted]ហុងវីង ទុកជាត្រឹមត្រូវតាម ទម្រង់ច្បាប់ តែបដិសេធចោលដោយមាសនីងគតិច្បាប់ ។

**២**_តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៤ "ខ" ចុះថ្ងៃទី ០៩-៣-២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ដោយគ្រាន់តែកែតម្រូវក្នុងចំណុចទី១ នូវបទល្មើសជួញដូរមនុស្ស មកជា បទល្មើសលក់ទិញដូរមនុស្សដោយមានគោលដៅ តាមមាត្រា ១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងបទ សញ្ចារកម្មទាក់ទង នឹងពេស្យាចារកុមារ តាមមាត្រា ២៨ នៃច្បាប់ដដែល ព្រមទាំង កែតម្រូវក្នុងចំណុចទី ២ នូវបទប្រព្រឹត្តអំពើអនាចារលើកុមារ មកជា បទ ទិញពេស្យាចារកុមារ វិញ តាមមាត្រា ៣៤ នៃច្បាប់ដដែល ។



Scanned by CamScanner

៣-បន្ទុំខ្លួនជនជាប់ចោទឈ្មោះ [redacted] Heninz . [redacted] Thomas ឈ្មោះ [redacted] ធីយ៉ីវ ឈ្មោះ [redacted] ហុងវិង និង ឈ្មោះ [redacted] ទី ។

៤-សាលដីកានេះជំនុំជំរះជាអសាធារណៈ នៅថ្ងៃទី ៣០-៧-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] Thomas និងឈ្មោះ [redacted] ហុងវិង និងមេធាវីការពារ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] Heninz ឈ្មោះ [redacted] ធីយ៉ីវ និង ឈ្មោះ [redacted] ទី ចំពោះមុខមេធាវីការពារ និង ចំពោះមុខជនរងគ្រោះ [redacted] ចាន់ណា . [redacted] ចាន់ធី និង [redacted] ធីតឹមធី និងមេធាវីការពារ ប្រកាសជាសាធារណៈនៅថ្ងៃទី ០៣-៨-២០០៩ បើកផ្លូវប្តឹងទាស់ និងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

## នាពេលសវនាការ

### -ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង

-ជនជាប់ចោទឈ្មោះ [redacted] Heninz ថា : ខ្ញុំស្គាល់ឈ្មោះ [redacted] ធីយ៉ីវ តាំងពីឆ្នាំ១៩៨៥ ឈ្មោះ នេះ ជាអ្នកបោសសំអាតផ្ទះរបស់ខ្ញុំ ខ្ញុំពិតជាឱ្យលុយនាងមែន នៅពេលនាងមកសំអាតផ្ទះខ្ញុំ ។ នៅថ្ងៃមួយពេលនាងឈឺបានឱ្យប្រាក់នាងចំនួន ២៥០ ដុល្លា ម្តង យកទៅព្យាបាលជំងឺ ក្មេងស្រីទាំងអស់នេះខ្ញុំពិតជាមិនស្គាល់ ព្រោះពួកគេមកលេងកំព្យូទ័រនៅផ្ទះរបស់ខ្ញុំ ខ្ញុំមិនបានរួមរ័ក្សជាមួយក្មេងស្រីទាំអស់នោះទេ ខ្ញុំស្គាល់ក្មេងនោះមិនមែនតាមរយៈឈ្មោះ [redacted] ធីយ៉ីវ ទេ ។ [redacted] ធីយ៉ីវ មិនដែលនាំក្មេងទាំងនោះមកផ្ទះរបស់ខ្ញុំទេ ខ្ញុំធ្លាប់ឱ្យលុយទៅក្មេងទាំងនោះ ពីព្រោះពួកវាធ្លាប់សំអាតផ្ទះរបស់ខ្ញុំ រូបថតនៅក្នុងកំព្យូទ័រនេះមានតែ [redacted] Thomas ដែលអ្នកធ្លាប់ជុសជុលឱ្យខ្ញុំ រូបថតដែលលោកចៅក្រមយកមកបង្ហាញនេះ ក៏មិនមានរូបថតខ្ញុំដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] ធីយ៉ីវ ថា : ខ្ញុំធ្លាប់ស្គាល់ [redacted] Heninz រាប់អានគាត់ជាមិត្តភក្តិ ជាយូរមកហើយ ខ្ញុំទៅសំអាតផ្ទះឱ្យគាត់ គាត់បានឱ្យប្រាក់មកខ្ញុំ ០១ ដង ៥ដុល្លា ពេលខ្ញុំឈឺគាត់ពិតជាបានឱ្យប្រាក់ខ្ញុំចំនួន ២៥០ ដុល្លា មួយដង ដើម្បីឱ្យថ្លៃថ្នាំព្យាបាល ។ ក្មេងស្រីទាំងនេះខ្ញុំធ្លាប់នាំទៅផ្ទះគាត់មួយដងឱ្យទៅជួយសំអាតផ្ទះឱ្យគាត់ ក្រោយមកទៀតខ្ញុំមិនដឹងទេ ខ្ញុំមិនបាននាំក្មេងស្រីទាំងអស់នេះមកលក់ឱ្យ [redacted] Heninz ទេ ។

-ឈ្មោះ [redacted] ទី ថា : ខ្ញុំជាជាងធ្វើតុ ទូ នៅម្តុំបឹងត្របែក ធ្វើការរហូតពេញ ០១ ថ្ងៃ មិនបានដឹងអ្វីទេ ខ្ញុំមិនបានយកកូនស្រីរបស់ខ្ញុំទាំងពីរនាក់នេះ ទៅលក់ឱ្យ [redacted] Heninz ទេ ហើយក៏មិនបានទទួលប្រាក់ ៥០០ ដុល្លា នោះដែរ ។ កូនស្រីខ្ញុំទាំងពីរនាក់មិនដែលបាត់ចោលពីផ្ទះ ០១ ថ្ងៃណាឡើយ ។

ដោយជីវភាពខ្ញុំក្រលំបាកពេក មានស្ត្រីម្នាក់មកនាំកូនស្រីខ្ញុំទៅរៀនកំព្យូទ័រ ខ្ញុំក៏សុខចិត្តឱ្យទៅ ។

### តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន



Scanned by CamScanner

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់ ( សំភារៈរឹបអូសបាន រូបថត ) សាលដីការបស់សាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវ សុំតម្កល់ទុកជាបានការ ។

**មេធាវីការពារជនជាប់ចោទ [redacted] Heninz , [redacted] ធីយ៉ា , [redacted] ហុងវីង ធ្វើសេចក្តីសន្និដ្ឋាន**

[redacted] Heninz គាត់មិនបានប្រព្រឹត្តទៅលើកុមារីទាំងអស់នោះទេ នៅពេលសវនាការក៏គាត់បានបញ្ជាក់ដែរ មិនបានទទួលស្គាល់រូបថតនេះទេ សុំលោកចៅក្រមពិនិត្យពិចារណាទៅលើចម្លើយនៅប៉ូលីស ព្រោះជនរងគ្រោះធ្លាប់លក់ខ្លួនម្តងមកហើយ មុននឹងមកជួប [redacted] Heninz ។

-ឈ្មោះ [redacted] ធីយ៉ា ថា : គ្មានភស្តុតាងណាមួយបញ្ជាក់ថា កូនក្តីខ្ញុំជាអ្នកទិញ ជាអ្នកលក់ឱ្យទៅអ្នកណាទេ ។ សុំឱ្យ រួចផុតពីការចោទប្រកាន់ ។

**មេធាវីការពារជនជាប់ចោទ [redacted] នី ធ្វើសេចក្តីសន្និដ្ឋាន**

កូនក្តីខ្ញុំមិនបានយកកូនទៅលក់ឱ្យ [redacted] Heninz ទេ ព្រោះជាប់ធ្វើការរហូតពេញ ០១ ថ្ងៃ ។ សុំឱ្យរួចផុតពីបទ ចោទ ។

**មេធាវីការពារជនរងគ្រោះ ធ្វើសេចក្តីសន្និដ្ឋាន**

មានចម្លើយរបស់កូនក្តីខ្ញុំនៅក្នុងសំណុំរឿងរួចមកហើយ ខ្ញុំសុំឱ្យក្រុមប្រឹក្សាជំនុំជំរះសំរេចឱ្យមានសំណងដល់កូនក្តីរបស់ខ្ញុំ ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យ ឯកសារក្នុងសំណុំរឿងហើយ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និង សំណូមពរ ។

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

ក្រោពីបានស្តាប់ការធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ។

ក្រោយពីបានស្តាប់ការធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ ។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា</u> :**

១-បណ្តឹងទាស់ ចុះថ្ងៃទី ១៧-០៨-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] Heninz ឈ្មោះ [redacted] នី . ឈ្មោះ [redacted] ធីយ៉ា នឹងសាលដីកាព្រហ្មទណ្ឌលេខ ៨៥ "ក" ចុះថ្ងៃទី ០៣-០៨-២០០៩ របស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned by CamScanner

២. លទ្ធផលនៃការអង្កេតរបស់សាលាដំបូងក្រុងភ្នំពេញ បានបង្ហាញនូវភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទទាំង ៣ រូបនេះ ដែលជាដើមបណ្តឹងទាស់ ។

៣. សំភារៈដែលរឹបអូសបាន ត្រូវបានប្រគល់ឱ្យមន្ត្រីនគរបាលព្រហ្មទណ្ឌអាល្លឺម៉ង់ ដែលបានបញ្ជាក់លើរំលោភផ្លូវភេទ ដែលជនជាប់ចោទឈ្មោះ [redacted] Heninz បានប្រព្រឹត្តលើកុមារី តូចៗទាំងនោះ ។

៤. ជនជាប់ចោទឈ្មោះ [redacted] Heninz បានទិញកុមារី [redacted] ចាន់ថា យកមកគ្រប់គ្រងបង្ខាំងទុកក្នុងផ្ទះអស់រយៈពេល ០១ អាទិត្យ ដើម្បីបង្ខំឱ្យរួមភេទជាមួយខ្លួន ដោយប្រើវិធីចងដៃ ចងជើង គំរាមកំហែងនឹងខ្សែរំពាត់ (ដែលត្រូវបានរឹបអូស និងឃើញក្នុងរូបថត) យកកន្សែងញាកមាត់កុំឱ្យយំ វិធីទាំងអស់នេះអាចឱ្យកំណត់បានថា ជាវិធីធ្វើទារុណកម្ម ។ ចំពោះកុមារីដទៃទៀត ក៏ជនជាប់ចោទបង្ខិតបង្ខំឱ្យរួមភេទជាមួយខ្លួនដូចមានរូបថតបង្ហាញស្រាប់ ។

៥. ជនជាប់ចោទឈ្មោះ [redacted] ទី បានប្រកែកថា ខ្លួនមិនបានលក់កូនឈ្មោះ [redacted] ចាន់ធី និង [redacted] ចាន់ថា ឱ្យទៅឈ្មោះ [redacted] Heninz ទេ តែការទទួលប្រាក់ ៥០០ ដុល្លា ពីកូនឈ្មោះ [redacted] ចាន់ថា ដែលបានផ្តល់ចម្លើយក្នុងសវនាការនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ៣០-០៧-២០០៩ បញ្ជាក់បានថា ឈ្មោះ [redacted] ទី ពិត ជាទទួលប្រាក់កម្រៃពីការប្រគល់កូនខ្លួនទាំងពីនាក់ឱ្យទៅឈ្មោះ [redacted] Heninz ដើម្បីរួមភេទ ។ ឈ្មោះ [redacted] ទី ដោះសារថា ខ្លួនឱ្យកូនទៅលេងផ្ទះ [redacted] Heninz ដើម្បីរៀនភាសាអង់គ្លេស ដែលជាចម្លើយមិនអាចឱ្យជឿបានទេ ព្រោះថាម្តាយមិនអាចបណ្តោយកូនខ្លួននៅតូចៗទៅប្រាស្រ័យទាក់ទងជា ញឹកញាប់ជាមួយបុរសដែលខ្លួនមិនស្គាល់នោះទេ គឺពិតជាក្នុងគោលបំណងទាញអត្ថប្រយោជន៍ពីសកម្មភាពផ្លូវភេទ ។

៦. ឈ្មោះ [redacted] ធីយ៉ុវ ធ្លាប់បានដឹកជនរងគ្រោះជាមួយជនជាប់ចោទឈ្មោះ [redacted] ហុងវីង នាំទៅផ្ទះឈ្មោះ [redacted] Heninz ជាញឹកញាប់ ហើយបានទទួលកម្រៃពី [redacted] Heninz ក្នុងការជូនដូរកុមារីរងគ្រោះទាំងអស់នេះ ។

៧. សំអាងហេតុដែលលើកឡើងក្នុងសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ ៨៥ "ក" ចុះថ្ងៃទី ០៣-០៨-២០០៩ របស់សាលាឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងជនជាប់ចោទទាំង ០៣ រូបខាងលើនេះ សាលាឧទ្ធរណ៍រក្សាទុកនៅដដែល ។

៨. សាលដីកាព្រហ្មទណ្ឌលេខ ៨៥ "ក" ចុះថ្ងៃទី ០៣-០៨-២០០៩ របស់សាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ គប្បីតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងទាស់ ចុះថ្ងៃទី ១៧-០៨-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] **ធីយ៉ុវ** , ឈ្មោះ [redacted] **Heninz** , ឈ្មោះ [redacted] ទី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។



115

Scanned by CamScanner

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៨៥ "ក" ចុះថ្ងៃទី ០៣-៨-២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] Heninz . ឈ្មោះ [redacted] ធីយីវ និងឈ្មោះ [redacted] ទី ។

៤-សាលដីកានេះជំនុំជំរះជាអសាធារណៈ នៅថ្ងៃទី ៣១-៣-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] Heninz . ឈ្មោះ [redacted] ធីយីវ និង ឈ្មោះ [redacted] ទី មេធាវីការពារជនជាប់ចោទ និង មេធាវីការពារជនរងគ្រោះ ប្រកាសជាសាធារណៈនៅថ្ងៃទី ០២-៤-២០១០ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា : [redacted] | ហត្ថលេខា : [redacted] . [redacted] | ហត្ថលេខា [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី ...០៦... ខែ..៤... ឆ្នាំ ២០១០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ



116